# កូនសៀវភៅណែនាំនៃកម្មវិធី
# WELFARE TO WORK
# (កម្មវិធីជួយឱ្យចេញពី
# ជំនួយសុខុមាលភាពទៅធ្វើការ)

[*Replace with county's title for handbook*]

**CAMBODIAN**

# កូនសៀវភៅណែនាំនៃ
# កម្មវិធីជួយឱ្យចេញពីជំនួយសុខុមាលភាពទៅធ្វើការ

[*Replace with county's title for handbook.*]

## តើកម្មវិធីជួយឱ្យចេញពីជំនួយសុខុមាលភាពទៅធ្វើការជាអ្វី និងតើកម្មវិធីនេះអាចធ្វើអ្វីខ្លះជូនលោកអ្នក

គោលបំណងនៃកម្មវិធីជួយឱ្យចេញពីជំនួយសុខុមាលភាពទៅធ្វើការ (Welfare to Work) គឺជួយចំពោះលោកអ្នករៀបចំខ្លួនដើម្បីធ្វើការ និងស្វែងរកការងារធ្វើ ។ ការរកបានការងារធ្វើនឹងជួយលោកអ្នកឱ្យក្លាយទៅជាអ្នកផ្គត់ផ្គង់ខ្លួនដោយខ្លួនឯង ហើយគ្រួសាររបស់លោកអ្នកនឹងមានសេចក្តីរីករាយនឹងជីវភាពដែលប្រសើរជាងមុន ។ បន្ទាប់ពីលោកអ្នកទទួលការងារធ្វើ លោកអ្នកនឹងមានប្រាក់ច្រើនជាងមុនសំរាប់គ្រួសាររបស់លោកអ្នក ធ្វើជាគំរូដ៏ប្រសើរសំរាប់កូនរបស់លោកអ្នក បង្កើននូវជំនឿទៅលើខ្លួនរបស់លោកអ្នក និងកសាងនូវអនាគតរបស់លោកអ្នក ។

គេបានបង្កើតកម្មវិធី Welfare to Work នេះដោយមានការគិតគូរចំពោះលោកអ្នក ។ កម្មវិធីនេះមិនត្រឹមតែជាកម្មវិធីមួយទៀតរបស់រដ្ឋាភិបាលតែប៉ុណ្ណោះ ។ គឺជាកម្មវិធីថ្មីមួយដែលអាចជួយចំពោះលោកអ្នក ។

- បុគ្គលិកនៃកម្មវិធី Welfare to Work ធ្វើការជាមួយលោកអ្នកគ្រប់ជំហាន ដោយផ្តល់ជូនលោកអ្នកនូវកិច្ចជួយផ្គត់ផ្គង់សំខាន់ៗ ដូចជាកិច្ចថែរក្សាក្មេង យានដឹកនាំ និងការចំណាយទាក់ទងទៅនឹងការងារ ឬការហ្វឹកហ្វឺន ។
- កម្មវិធី Welfare to Work អាចជួយលោកអ្នកឱ្យរកបានការងារដែលលោកអ្នកត្រូវការដើម្បីគ្រប់គ្រងខ្លួនដោយខ្លួនឯង ។ បើសិនជាលោកអ្នកត្រូវការ លោកអ្នកនឹងសិក្សានូវជំនាញការដែលនឹងជួយលោកអ្នករកបានការងារធ្វើនៅក្នុងកន្លែងធ្វើការសព្វថ្ងៃនេះ ឬនៅក្នុងទីផ្សារក្នុងតំបន់របស់លោកអ្នក ។
- កម្មវិធី Welfare to Work អាចជួយលោកអ្នកឱ្យបង្កើននូវឱកាសក្នុងការទទួលការងារធ្វើ ជាមួយរោងឧស្សាហកម្មឯកជន កន្លែងជំនួញ ឬកន្លែងធ្វើការបំរើសាធារណៈនៅក្នុងតំបន់របស់លោកអ្នក ។

តាមរយៈកម្មវិធី Welfare to Work យើងទាំងអស់គ្នាមានជោគជ័យ ។ លោកអ្នកទទួលការងារធ្វើនិងមានអានាគត ។ ម្ចាស់ការងារចំរើននូវកម្លាំងធ្វើការដែលមានជំនាញការ ។

## អ្នកណាដែលត្រូវតែចូលរួម?

**<u>អ្នកចូលរួមជាចាំបាច់</u>** ។ បើសិនជាលោកអ្នកគឺជាអ្នកទទួលជំនួយនៃកម្មវិធីជួយឱ្យធ្វើការនិងទទួលខុសត្រូវចំពោះកូននៃរដ្ឋកាលីហ្វ័រនីញ៉ា (California Work Opportunity and Responsibility to Kids ឬ CalWORKs) ហើយដែលលោកអ្នកមិនត្រូវបានលើកលែង លោកអ្នកត្រូវតែចូលរួមជាមួយកម្មវិធី Welfare to Work ។ លោកអ្នកត្រូវបានគេហៅថា "អ្នកចូលរួមជាចាំបាច់" ។ បើសិនជាលោកអ្នកគឺជាអ្នកចូលរួមជាចាំបាច់ លោកអ្នកត្រូវ :

- រក្សាការណាត់ជួបដែលបានធ្វើឡើងដោយអ្នកកាន់សំណុំរឿងនៃកម្មវិធី Welfare to Work របស់លោកអ្នក ។
- ចុះហត្ថលេខានៅលើគ្រោងការ Welfare to Work ។
- ធ្វើតាមការតម្រូវទាំងអស់នៃកម្មវិធី Welfare to Work ដោយគិតបញ្ចូលទាំងការតម្រូវនៅក្នុងគ្រោងការនៃកម្មវិធី Welfare to Work ។

- មិនលះបង់ការងាររបស់លោកអ្នក ឬបន្ថយប្រាក់រកបានរបស់លោកអ្នក និង

- ផ្តល់នូវភស្តុតាងនៃការរីកចំរើនដោយគួរសមនៅក្នុងសកម្មភាពដែលបានចាត់ឱ្យធ្វើរបស់លោកអ្នក បើសិនជាបានតម្រូវ ។

យើងនឹងសំរេចថាតើ លោកអ្នកត្រូវចូលរួមជាមួយកម្មវិធី Welfare to Work ឬក៏យ៉ាងណានៅពេលដែល :

- លោកអ្នកដាក់ពាក្យសុំជំនួយ

- ការទទួលជំនួយរបស់លោកអ្នកត្រូវបានកំណត់សាជាថ្មី ឬ

- លោកអ្នកមានការផ្លាស់ប្តូរមួយនៅលើស្ថានភាពលើកលែងរបស់លោកអ្នក ។

**អ្នកចូលរួមដោយស្ម័គ្រចិត្ត** ទោះបីជាលោកអ្នកត្រូវបានលើកលែងហើយមិនបាច់ចូលរួមជាមួយកម្មវិធី Welfare to Work ក៏ដោយ ក៏លោកអ្នកអាចសុំចូលរួមបានដែរ ។ គេនឹងហៅលោកអ្នកថាជា "អ្នកចូលរួមដោយស្ម័គ្រចិត្ត" ។ សូមសាកសួរអ្នកកាន់សំណុំរឿងរបស់លោកអ្នកអំពីរបៀបដែលលោកអ្នកអាចចូលរួមជាមួយកម្មវិធី Welfare to Work ។

**កម្មវិធីពិសោធន៍** - ខណ្ឌមួយចំនួនគឺជាផ្នែកមួយនៃកម្មវិធីពិសោធន៍ ។ កម្មវិធីពិសោធន៍ទាំងនេះប្រើច្បាប់សាកល្បងប្លែកៗពីគ្នា ដើម្បីពិនិត្យថាតើច្បាប់ណាដែលអនុវត្តបានប្រសើរជាងគេ ។ អ្នកកាន់សំណុំរឿងនៃកម្មវិធី Welfare to Work របស់លោកអ្នកនឹងពន្យល់ បើសិនជា [*insert the name of the county*] គឺជាផ្នែកមួយនៃកម្មវិធីពិសោធន៍ និងបើសិនជាមានច្បាប់ណាមួយខុសប្លែកពីច្បាប់នៅក្នុងសៀវភៅ [*insert the county's title for the Welfare to Work Handbook*] ដែលដាក់អនុវត្តចំពោះលោកអ្នក ។

# អ្នកណាខ្លះដែលមិនបាច់ចូលរួម?

## ការលើកលែង

លោកអ្នកត្រូវបានគេលើកលែងហើយមិនបាច់ចូលរួមជាមួយកម្មវិធី Welfare to Work បើសិនជាលោកអ្នក :

- មានអាយុតិចជាង១៦ឆ្នាំ ហើយមិនមែនជាឪពុកម្តាយដែលជាអ្នកអាណាព្យាបាល ឬអាយុ៦០ឆ្នាំឬច្រើនជាង ។

- មានអាយុ១៦ ១៧ ឬ១៨ឆ្នាំហើយទៅសាលារៀន(មិនមែនមហា វិទ្យាល័យ)ពេញពេល លើកលែងតែលោកអ្នកនៅក្នុងសាលានោះ គឺជាផ្នែកមួយនៃសកម្មភាព Welfare to Work របស់លោកអ្នក ឬលោកអ្នកគឺជាឪពុកម្តាយដែលជាអ្នកអាណាព្យាបាល ។

- មានភាពពិការដែលសង្ឃឹមថាមានរយៈពេលយ៉ាងតិចណាស់៣០ថ្ងៃ និងដែលឃាត់យ៉ាងមិនឱ្យលោកអ្នកធ្វើការបាន ឬចូលរួមនៅក្នុងសកម្មភាពនៃកម្មវិធី Welfare to Work ហើយដែលលោកអ្នកកំពុងទទួល ឬព្យាយាមធ្វើឱ្យបានកិច្ចព្យាបាលផ្នែកពេទ្យដែលលោកអ្នកត្រូវការ (ការលើកលែងនេះមិនអាចអនុវត្តបានទេ បើសិនជាលោកអ្នកគឺជាឪពុកម្តាយជាក្មេងជំទង់ដែលបានតម្រូវឱ្យចូលរួមជាមួយកម្មវិធីសិក្សាអប់រំនៃរដ្ឋកាលីហ្វ័រនីញ៉ាជួយចំពោះឪពុកម្តាយជាក្មេងជំទង់ដែលទទួលប្រាក់ជំនួយ (Cal-Learn)) ។

- មានផ្ទៃពោះ ហើយដែលវេជ្ជបណ្ឌិតថ្លែងថា លោកអ្នកមិនអាចធ្វើការ ឬចូលរួមនៅក្នុងសកម្មភាពនៃកម្មវិធី Welfare to Work (ការលើកលែងនេះមិនអាចអនុវត្តបានទេ បើសិនជាលោកអ្នកគឺជាឪពុកម្តាយជាក្មេងជំទង់ដែលបានតម្រូវឱ្យចូលរួមជាមួយកម្មវិធី Cal-Learn) ។

- ជាអ្នកថែរក្សាជាសាច់ញាតិដែលមិនមែនជាឳពុកម្ដាយនៃក្មេងដែលនៅក្នុងបន្ទុក ឬនៅក្នុងការគ្រប់គ្រងនៃតុលាការ ឬជាក្មេងដែលអាចធ្លាក់ទៅក្នុងកន្លែងថែរក្សាកូនចិញ្ចឹម ហើយដែលយើងសំរេចថា ការថែរក្សាក្មេងនាំឱ្យលោកអ្នកធ្វើការមិនបាន ឬមិនអាចចូលរួមជាមួយសកម្មភាព នៃកម្មវិធី Welfare to Work នៅតាមពេលវេលាជាធម្មតា ។

- ត្រូវតែនៅផ្ទះដើម្បីថែរក្សាអ្នកណាម្នាក់នៅក្នុងគ្រួសារដែលមិនអាចថែរក្សាខ្លួនឯងបាន បើសិនជាកិច្ចការនេះនាំឱ្យលោកអ្នកធ្វើការមិនបាន ឬមិនអាចចូលរួមជាមួយសកម្មភាពនៃកម្មវិធី Welfare to Work នៅតាមពេលវេលាជាធម្មតា (ការលើកលែងនេះមិនអាចអនុវត្តបានទេ បើសិនជាលោកអ្នកគឺជាឳពុកម្ដាយជាក្មេងជំទង់ដែលបានតម្រូវឱ្យចូលរួមជាមួយ កម្មវិធីសិក្សាអប់រំនៃរដ្ឋកាលីហ្វ័រនីញ៉ាជួយចំពោះឳពុកម្ដាយជាក្មេងជំទង់ដែលទទួលប្រាក់ជំនួយ (Cal-Learn)) ។

- ជាឳពុកម្ដាយ ឬជាអ្នកថែរក្សាជាសាច់ញាតិដទៃទៀតនៃក្មេងអាយុ៦ខែឬតិចជាង និងជាអ្នកផ្ដល់កិច្ចថែរក្សាដោយផ្ទាល់ចំពោះក្មេងដោយមានការកំរិតដូចតទៅនេះ :

  - លោកអ្នកអាចទទួលការលើកលែងសំរាប់មូលហេតុនេះបានតែម្ដងទេ នៅក្នុងកំឡុងពេលជាប់បន្តគ្នានៃការទទួលជំនួយពីកម្មវិធី CalWORKs ។

  - បើសិនជាលោកអ្នកបានទទួលការលើកលែងនេះពីមុនមក ហើយអ្នកសំរាលកូនឬសុំកូនគេមកចិញ្ចឹមដែលមានអាយុ៦ខែ ឬតិចជាង លោកអ្នកអាចត្រូវបានលើកលែងសំរាប់ពេល១២សប្ដាហ៍ ។

  - បើសិនជាលោកអ្នកគឺជាឳពុកម្ដាយដែលជាក្មេងជំទង់ដែលបានតម្រូវឱ្យចូលរួមជាមួយកម្មវិធី Cal-Learn ការលើកលែងនេះមិនអាចយកមកប្រើបានទេ ។

យើងអាចសួរលោកអ្នករកភស្ដុតាង នៅពេលដែលលោកអ្នកទាមទារថាមានការលើកលែងណាមួយដូចមាននៅខាងលើនេះ ។ អ្នកកាន់សំណុំរឿងនៃកម្មវិធីរបស់លោកអ្នកអាចពិនិត្យនៅលើស្ថានភាពរបស់លោកអ្នកបានគ្រប់ពេល ។

[*If the county elects to reduce and/or increase this period from 12 weeks to 12 months, insert language describing the period and the criteria for determining it.*]

# កម្មវិធីជួយឱ្យចេញពីជំនួយសុខុមាលភាពទៅធ្វើការ

របៀបចូលរួមគឺមានជាច្រើនយ៉ាងសំរាប់អ្នកចូលរួមជាមួយកម្មវិធី Welfare to Work ។ របៀបចូលរួមរបស់លោកអ្នកអាចមិនបានជាប់ទាក់ទងទៅនឹងសកម្មភាពគ្រប់បែបនៃកម្មវិធី Welfare to Work ទេ ។ ភាគច្រើនគឺអាស្រ័យទៅលើចំណេះវិជ្ជា និងប្រវត្តិការងាររបស់លោកអ្នក ។ សកម្មភាពទាំងឡាយដែលកម្មវិធី Welfare to Work ផ្ដល់ជូនគឺមានរៀបរាប់នៅខាងក្រោម ។ សូមចងចាំថា គោលបំណងនៃកម្មវិធី Welfare to Work គឺជួយលោកអ្នករៀបចំខ្លួនដើម្បីការងារ និងរកបានការងារធ្វើ ដែលលោកអ្នកអាចផ្គត់ផ្គង់ខ្លួនឯងហើយនិងគ្រួសាររបស់លោកអ្នក ។

**ការកំណត់ (APPRAISAL)** – នៅពេលដែលលោកអ្នកចាប់ផ្ដើមចូលរួមជាមួយកម្មវិធី Welfare to Work លោកអ្នកនឹងអញ្ជើញទៅទទួលការកំណត់មួយ ។ នៅពេលធ្វើការកំណត់នេះ អ្នកកាន់សំណុំរឿងនៃកម្មវិធី Welfare to Work របស់លោកអ្នកនឹងពិនិត្យលើប្រវត្តិការងារ និងចំណេះវិជ្ជារបស់លោកអ្នក សេចក្ដីត្រូវការកិច្ចជួយផ្គត់ផ្គង់ ហើយនិងពត៌មានដទៃទៀតដើម្បីជួយខណ្ឌសំរេចថាតើសកម្មភាព Welfare to Work របស់លោកអ្នកគឺជាអ្វី ឬនឹងជាអ្វី ។

**កិច្ចស្វែងរកការងារ (JOB SEARCH)** – បន្ទាប់ពីការកំណត់ អ្នកចូលរួមភាគច្រើននឹងត្រូវបានចាត់ឱ្យទៅចូលរួមជាមួយសកម្មភាពស្វែងរកការងារដែលមានរយៈពេលរហូតដល់ទៅ៤សប្តាហ៍ ។ ក៏ប៉ុន្តែសកម្មភាពស្វែងរកការងារនេះអាចមានរយៈពេលយូរ ឬឆាប់ជាង បើសិនជាខណ្ឌហើយនិងលោកអ្នកព្រមព្រៀងថានឹងជាផលប្រយោជន៍ចំពោះលោកអ្នក ។ [*Insert county's listing and description of specific job search services that it provides.*]

អ្នកចូលរួមដូចតទៅនេះនឹងមិនបានតម្រូវឱ្យចូលរួមជាមួយសកម្មភាពស្វែងរកការងារធ្វើបន្ទាប់ពីការកំណត់ទេ ប៉ុន្តែគេអាចស្នើសុំចូលរួមបានដែរ :

- ជាអ្នកដែលកំពុងធ្វើការនៅក្នុងការងារដែលមិនទទួលប្រាក់ជំនួយមួយ ឬដែលកំពុងតែចូលរួមនៅក្នុងកម្មវិធីដែលផ្តើមដោយខ្លួនឯងដែលទទួលយល់ព្រម (Self-Initiated Program ឬ SIP) បើសិនជាកាលវិភាគនៃការស្វែងរកការងារនឹងនាំឱ្យគាត់មិនអាចធ្វើការបាន ឬចូលរួមជាមួយកម្មវិធីដែលផ្តើមដោយខ្លួនឯង ឬ

- ឪពុកម្តាយជាក្មេងជំទង់បានតម្រូវឱ្យចូលរួមជាមួយកម្មវិធី Cal-Learn ឬឪពុកម្តាយជាអ្នកអាណាព្យាបាលដែលមានអាយុ១៩ឆ្នាំ ដែលមិនមានសញ្ញាបត្រមធ្យមសិក្សា ឬសញ្ញាបត្រចំណេះវិជ្ជាទូទៅ (General Educational Development ឬ GED) ។

**ការប្រមាណប៉ាន់ (ASSESSMENT) –** បើសិនជាលោកអ្នកមិនទទួលការងារដែលទទួលប្រាក់ជំនួយនៅក្នុងពេលលោកអ្នកចូលរួមជាមួយការស្វែងរកការងារ បើសិនជាយើងសំរេចថា ការបញ្ជូនលោកអ្នកទៅសកម្មភាពស្វែងរកការងារជាសកម្មភាពដំបូងរបស់លោកអ្នកនឹងមិនជួយចំពោះលោកអ្នកទេ ឬបើសិនជាយើងសំរេចថាបន្ថយពេលចូលរួមរបស់លោកអ្នកជាមួយសកម្មភាពស្វែងរកការងារ ពីព្រោះតែសកម្មភាពនេះនឹងប្រហែលជាមិនបាននាំឱ្យលោកអ្នកទទួលការងារធ្វើ លោកអ្នកនឹងត្រូវបានគេបញ្ជូនឱ្យទៅសកម្មភាពប្រមាណប៉ាន់ ។ គោលបំណងនៃការប្រមាណប៉ាន់នេះ គឺដើម្បីឱ្យលោកអ្នកនិងខណ្ឌរៀបចំរួមគ្នានូវ**គ្រោងការនៃកម្មវិធីជួយឱ្យចេញពីជំនួយសុខុមាលភាពទៅធ្វើការ (Welfare to Work)** មួយដែលនឹងជួយលោកអ្នកឱ្យរកបានការងារធ្វើ ។ ដើម្បីធ្វើដូចនេះ អ្នកធ្វើការប្រមាណប៉ាន់នឹងពិនិត្យមើលអំពីសមត្ថភាពរបស់លោកអ្នក ការចាប់អារម្មណ៍ ប្រវត្តិការងារ ហើយនិងចំណេះវិជ្ជា សេចក្តីត្រូវការកិច្ចជួយផ្គត់ផ្គង់ ដើម្បីទទួលនូវផលប្រយោជន៍ជាអតិបរមាពីការងារ និងកិច្ចជួយផ្នែកហ្វឹកហ្វឺនដែលបានផ្តល់ឱ្យដោយកម្មវិធី Welfare to Work ការប្រម៉ាណអំពីឱកាសអាចទទួលការងារធ្វើដោយការផ្តល់នូវជំនាញការរបស់លោកអ្នក ហើយនិងការងារដែលមាននៅក្នុងតំបន់របស់លោកអ្នក បញ្ហាផ្នែករូបរាងកាយនិងសតិអារម្មណ៍ដែលលោកអ្នកអាចមាន ដែលកម្រិតនូវសមត្ថភាពក្នុងការធ្វើការងាររបស់លោកអ្នក ឬចូលរួមនៅក្នុងសកម្មភាពនៃកម្មវិធី Welfare to Work និងបញ្ជីនៃកិច្ចជួយ ដែលខណ្ឌមាន ឬអាចរកជូនលោកអ្នក ដែលលោកអ្នកអាចបញ្ចប់នូវគ្រោងការ Welfare to Work របស់លោកអ្នក ។

បើសិនជាលោកអ្នកនៅក្នុងកម្មវិធីដែលផ្តើមឡើងដោយខ្លួនឯង គ្រោងការនៃកម្មវិធី Welfare to Work អាចត្រូវបានរៀបចំឡើងដោយអាស្រ័យទៅលើការកំណត់របស់លោកអ្នក ។ ក៏ប៉ុន្តែ លោកអ្នកអាចត្រូវបានបញ្ជូនទៅធ្វើការប្រមាណប៉ាន់ បើសិនជាយើងត្រូវការបញ្ជូនលោកអ្នកទៅកាន់សកម្មភាពដទៃទៀតនៅក្នុងពេលជាមួយគ្នា ដែលលោកអ្នកនឹងចូលរួមជាមួយសកម្មភាពនៃកម្មវិធី Welfare to Work សំរាប់ចំនួនម៉ោងបានតម្រូវឱ្យលោកអ្នកចូលរួម ។

## *សកម្មភាពនៃកម្មវិធី Welfare to Work*

### ការងារដែលមិនមានផ្តល់ប្រាក់ជំនួយ

### ការងារនៃកន្លែងឯកជនដែលទទួលប្រាក់ជំនួយ

### ការងារនៃកន្លែងសាធារណៈការដែលទទួលប្រាក់ជំនួយ

### ការពិសោធន៍ធ្វើការងារ

### កិច្ចការក្នុងសហគមន៍

**ការហ្វឹកហ្វឺននៅលើការងារ**

**ប្រាក់ជំនួយដោយយោងទៅលើការហ្វឹកហ្វឺននៅលើការងារ**

**ការងារជាដំណាក់ការ**

**ការងារដែលទទួលកិច្ចជួយ**

**កម្មសិក្សាធ្វើការងារ**

**កម្មវិធីដែលផ្តើមដោយខ្លួនឯង**

**ការសិក្សាអប់រំជាមូលដ្ឋានសំរាប់មនុស្សពេញវ័យ**

**ការហ្វឹកហ្វឺនជំនាញការលើការងារដែលជាប់ទាក់ទងដោយផ្ទាល់ទៅនឹងការហ្វឹកហ្វឺន**

**ការហ្វឹកហ្វឺនផ្នែកមុខវិជ្ជាជីវៈ**

**ការស្វែងរកការងារនិងកិច្ចជួយរៀបចំខ្លួនឱ្យរួចជាស្រេចសំរាប់ការងារ**

**ការសិក្សាអប់រំដែលជាប់ទាក់ទងដោយផ្ទាល់ទៅនឹងការងារ**

**ការសិក្សាអប់រំជាបន្ថែម ឬការបង្រៀនឱ្យទទួលសញ្ញាបត្រ GED សំរាប់អ្នកទទួលជំនួយដែលមិនមានសញ្ញាបត្រមធ្យមសិក្សា**

**កិច្ចជួយផ្នែកវិបត្តិសតិអារម្មណ៍ សារធាតុដែលផ្តល់ទុក្ខទោស និងការធ្វើបាបនៅក្នុងគ្រួសារ**

[*Insert county-developed descriptions of the welfare to work activities that they will provide to participants.*]

**ការកំណត់ជាថ្មី (REAPPRAISAL) –** បើសិនជាលោកអ្នកមិនបានទទួលការងារធ្វើបន្ទាប់ពីបានបញ្ចប់សកម្មភាពទាំងអស់ នេះដោយមានបញ្ចូលនៅក្នុងគ្រោងការ Welfare to Work របស់លោកអ្នក និងដែលលោកអ្នកបានមានការប្រមាណប៉ាន់មួយ លើកលែងតែលោកអ្នកបានទទួលជំនួយចំនួន១៨ខែ ឬ២៤ខែ លោកអ្នកនឹងត្រូវអញ្ជើញទៅកាន់ការកំណត់ជាថ្មី ។ នៅក្នុងការកំណត់ជាថ្មី យើងនឹងសំរេចថាតើមានកាលៈទេសៈពិសេសអ្វីមួយទេដែលរារាំងមិនឱ្យលោកអ្នករកការងារមិនបានធ្វើនៅក្នុងតំបន់របស់លោកអ្នក ។ បើសិនជាយើងសំរេចថា លោកអ្នកបានមានកាលៈទេសៈពិសេសមួយ លោកអ្នកនឹងត្រូវបានបញ្ជូនឱ្យទៅកាន់សកម្មភាពផងទៃទៀត ។ បើសិនជាយើងសំរេចថា លោកអ្នកមិនបានមានកាលៈទេសៈពិសេសអ្វីមួយទេ លោកអ្នកនឹងត្រូវចូលរួមជាមួយសកម្មភាពណាមួយដូចមាននៅខាងក្រោមនេះ :

- ការងារដែលមិនទទួលប្រាក់ជំនួយ ។
- ការពិសោធន៍ធ្វើការងារ ។

- ការហ្វឹកហ្វឺនជំនាញការការងារដែលទាក់ទងដោយផ្ទាល់ទៅនឹងការងារ ។
- កិច្ចជួយផ្នែកវិបត្តិសតិអារម្មណ៍ សារធាតុដែលផ្តល់ទុក្ខទោស និងឬការធ្វើបាបនៅក្នុងគ្រួសារ ។

## ម៉ោងចូលរួម

**គ្រួសារដែលមានតែឪពុកឬម្តាយ** – បើសិនជាលោកអ្នកគឺជាមនុស្សពេញវ័យនៅក្នុងសំណុំរឿងនៃកម្មវិធី CalWORKs ដែលមានតែឪពុកឬម្តាយ ហើយដែលលោកអ្នកមិនត្រូវបានលើកលែង លោកអ្នកនឹងត្រូវចូលរួមនៅក្នុងសកម្មភាពមួយឬច្រើននៃកម្មវិធី Welfare to Work ដែលចាត់ឱ្យចូលរួមរបស់លោកអ្នក សំរាប់ពេលសរុបយ៉ាងតិចណាស់២០ម៉ោងក្នុងមួយសប្តាហ៍ ។ ចាប់ផ្តើមពីថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៩៩ លោកអ្នកនឹងត្រូវចូលរួមសំរាប់ពេលយ៉ាងតិចណាស់៣២ម៉ោងក្នុងមួយសប្តាហ៍ ។ [*Counties that elect to implement the 32-hour requirement earlier than July 1, 1999 should modify the language to reflect the date when they will put this requirement into effect.*]

**គ្រួសារដែលមានទាំងឪពុកនិងម្តាយ** – បើសិនជាលោកអ្នកគឺជាមនុស្សពេញវ័យនៅក្នុងសំណុំរឿងនៃកម្មវិធី CalWORKs ដែលមានទាំងឪពុកនិងម្តាយ ហើយដែលលោកអ្នកមិនត្រូវបានលើកលែង លោកអ្នកហើយនិងឬឪពុកឬម្តាយម្ខាងទៀតដែលនៅក្នុងក្រុមគ្រួសារទទួលជំនួយរបស់លោកអ្នកនឹងត្រូវចូលរួមជាមួយសកម្មភាពនៃកម្មវិធី Welfare to Work ដែលចាត់ឱ្យចូលរួមរបស់លោកអ្នក សំរាប់ពេលសរុបយ៉ាងតិចណាស់៣៥ម៉ោងក្នុងមួយសប្តាហ៍ ។ **សំគាល់** : ឪពុកម្តាយទាំងពីរនាក់អាចរួមគ្នាចូលរួមដើម្បីបំពេញចំនួនតម្រូវ៣៥ម៉ោងបាន ប៉ុន្តែឪពុកឬម្តាយម្នាក់ត្រូវតែចូលរួមសំរាប់ពេលយ៉ាងតិចណាស់២០ម៉ោងក្នុងមួយសប្តាហ៍ ។ ជាមួយនេះផងដែរ ដើម្បីទទួលកិច្ចថែរក្សាក្មេង CalWORKs ដែលបានបង់ប្រាក់ឱ្យដោយសហពន្ធ លោកអ្នកហើយនិងឪពុកឬម្តាយម្ខាងទៀតនឹងត្រូវតែចូលរួមសំរាប់ពេលយ៉ាងតិចណាស់៥៥ម៉ោងក្នុងមួយសប្តាហ៍ លើកលែងតែលោកឬអ្នកជាអ្នកពិការ ឬក៏ត្រូវថែរក្សាក្មេងដែលមានភាពពិការយ៉ាងធ្ងន់ធ្ងរម្នាក់ ។

**សំគាល់** : ចំនួនម៉ោងនៃការតម្រូវឱ្យចូលរួមមិនអាចអនុវត្តបានទេ បើសិនជាលោកអ្នកចូលរួមជាមួយកម្មវិធី Cal-Learn ។

## ការចូលរួមជាមួយសកម្មភាពច្រើននៅក្នុងពេលតែមួយ

យើងអាចតម្រូវឱ្យលោកអ្នកចូលរួមជាមួយសកម្មភាពច្រើននៅក្នុងពេលតែមួយ បើសិនជាលោកអ្នកអាចធ្វើបាន ដោយសកម្មភាពនោះគឺសមស្របទៅនឹងគ្រោងការ Welfare to Work របស់លោកអ្នក ហើយនិងសកម្មភាពទាំងនោះអាចណាត់ពេលធ្វើនៅក្នុងពេលតែមួយ ។

## ការចូលរួមគួរជាទីពេញចិត្ត

**ការទៅចូលរួមសិក្សា** - នៅពេលដែលលោកអ្នកចុះហត្ថលេខាលើគ្រោងការ Welfare to Work របស់លោកអ្នក លោកអ្នកយល់ព្រមទៅកាន់សកម្មភាពរបស់លោកអ្នក ហើយនិងបញ្ចប់សកម្មភាពនោះ ។ [*Insert county criteria for attendance.*]

**ការរីកចំរើនគួរជាទីពេញចិត្ត** - អ្នកចូលរួមជាមួយកម្មវិធី Welfare to Work ត្រូវបានតម្រូវធ្វើឱ្យមានការចំរើនជាទីពេញចិត្តទៅលើសកម្មភាពដែលត្រូវបានគេចាត់ឱ្យទៅចូលរួម ។ [*Insert county criteria for satisfactory progress.*]

**ការបញ្ចប់បេសកកម្ម** - [*Insert county criteria for successful completion of assignment.*]

# កិច្ចជួយផ្គត់ផ្គង់

យើងយល់ថា លោកអ្នកអាចត្រូវការកិច្ចជួយផ្សេងទៀតក្រៅពីការហ្វឹកហ្វឺន និងការឱ្យឱវាទលើការងារ ដើម្បីចូលរួមឱ្យមានជោគជ័យនៅក្នុងកម្មវិធី Welfare to Work ។ ដោយហេតុនេះហើយបានជាខណ្ឌនឹងជួយលោកអ្នករៀបចំ និង/ឬបង់ថ្លៃថែរក្សាក្មេង យានដឹកនាំ និងការចំណាយទាក់ទងទៅនឹងការងារឬការហ្វឹកហ្វឺន ។ បើសិនជាគ្មានប្រភពនៃថវិការដទៃទៀតដើម្បីបង់ការចំណាយសំរាប់កិច្ចជួយផ្គត់ផ្គង់ទាំងអស់របស់លោកអ្នកទេ យើងនឹងបង់សំរាប់កិច្ចជួយផ្គត់ផ្គង់ដូចបានរៀបរាប់នៅខាងក្រោម ។

**ការបង់ប្រាក់ជាមុន** - បើសិនជាលោកអ្នកមានសិទ្ធិទទួលប្រាក់បង់សំរាប់កិច្ចជួយផ្គត់ផ្គង់នៃកម្មវិធី Welfare to Work ហើយលោកអ្នកត្រូវការប្រាក់បង់សំរាប់កិច្ចជួយផ្គត់ផ្គង់របស់នៅមុនពេលចាប់ផ្តើមសកម្មភាពរបស់លោកអ្នក យើងនឹងផ្តល់ប្រាក់បង់ឱ្យជាមុនជូនលោកអ្នក ។ តាមវិធីនេះ លោកអ្នកនឹងមិនខ្វះប្រាក់ ទោះបីជាសំរាប់តែពេលដ៏ខ្លីមួយក៏ដោយ ។

**សំគាល់** : ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៩៨ ប្រាក់បង់ជាមុនសំរាប់ថ្លៃថែរក្សាក្មេងនឹងបង់ដោយផ្ទាល់ទៅឱ្យអ្នកផ្តល់កិច្ចថែរក្សាក្មេង ។ យើងនឹងមិនអាចផ្តល់ប្រាក់បង់ជាមុនទៅឱ្យលោកអ្នកបានឡើយ ។

ប្រាក់ជំនួយសំរាប់កិច្ចជួយផ្គត់ផ្គង់គិតបញ្ចូលថ្លៃដូចតទៅនេះ :

- ថ្លៃថែរក្សាក្មេង បើសិនជាការថែរក្សាក្មេងគឺជាការចាំបាច់សំរាប់ឱ្យលោកអ្នកចូលរួមជាមួយសកម្មភាពនៃកម្មវិធី Welfare to Work ។ លោកអ្នកអាចទទួលកិច្ចថែរក្សាសំរាប់ក្មេងម្នាក់ៗដែលនៅក្នុងសំណុំរឿង CalWORKs របស់លោកអ្នក ដែលមានអាយុ១០ឆ្នាំ ឬតិចជាង ។ កូនរបស់លោកអ្នកដែលមានអាយុ១១ឆ្នាំ ឬ១២ឆ្នាំអាចទទួលប្រាក់បង់សំរាប់កិច្ចថែរក្សាក្មេង បើសិនជាមានប្រាក់ ។ ជាមួយនេះផងដែរ លោកអ្នកអាចទទួលកិច្ចថែរក្សាសំរាប់ក្មេងដែលនៅក្នុងផ្ទះរបស់លោកអ្នក ប៉ុន្តែមិននៅក្នុងសំណុំរឿង CalWORKs របស់លោកអ្នក បើសិនជាការមិនមានកិច្ចថែរក្សាក្មេងនាំឱ្យលោកអ្នកមិនអាចចូលរួមឬរកការងារធ្វើបាន ។ លោកអ្នកអាចជ្រើសរើសប្រភេទនៃកិច្ចថែរក្សាក្មេងដែលលោកអ្នកចង់បានដូចជា មណ្ឌលថែរក្សាក្មេង បងប្អូន មិត្តភក្តិ ឬក៏អ្នកជិតខាង ។ យើងមិនអាចបង់ប្រាក់សំរាប់កិច្ចថែរក្សាក្មេងបានទេ បើសិនជាលោកអ្នកជ្រើសរើសយកអ្នកណាដែលនៅក្នុងសំណុំរឿង CalWORKs របស់លោកអ្នក អ្នកអាណាព្យាបាលពេញច្បាប់ជាឪពុកឬម្តាយរបស់ក្មេង ឬអ្នកថែរក្សាណាដែលមានអាយុតិចជាង១៨ឆ្នាំ ។ ប្រាក់សំរាប់បង់អាចបង់ទៅឱ្យអ្នកផ្តល់កិច្ចថែរក្សាក្មេងដែលមានច្បាប់អនុញ្ញាត និងនៅក្នុងករណីខ្លះអាចបង់ទៅឱ្យអ្នកណាដែលមិនត្រូវការច្បាប់អនុញ្ញាត ។ បើសិនជាអ្នកផ្តល់កិច្ចថែរក្សាក្មេងរបស់លោកអ្នកមិនត្រូវការច្បាប់អនុញ្ញាត គាត់ត្រូវតែដាក់ពាក្យចុះឈ្មោះពិនិត្យមើលប្រវត្តិ លើកលែងតែអ្នកផ្តល់កិច្ចថែរក្សាក្មេងរបស់លោកអ្នកគឺជា មីង មា ឬជីដូនជីតារបស់ក្មេង ។ ចំនួនច្រើនបំផុតដែលយើងអាចបង់ឱ្យនោះ គឺជាកំរិតតម្លៃឈ្នួលដោយយោងទៅតាមតម្លៃថែរក្សាក្មេងជាធម្មតានៅកន្លែងដែលលោកអ្នករស់នៅ ។

- សោហ៊ុយសំរាប់យានដឹកនាំ ទៅតាមចំនួនដ៏ជាក់លាក់សំរាប់ការធ្វើដំណើរទៅមកពីកន្លែងបេសកកម្មនៃកម្មវិធី Welfare to Work របស់លោកអ្នក និងសំរាប់លោកអ្នកនិងកូនធ្វើដំណើរទៅនិងមកពីកន្លែងថែរក្សាក្មេង ។

- ការចំណាយទាក់ទងនឹងការងារ ឬការហ្វឹកហ្វឺនសំរាប់សៀវភៅ ប្រដាប់ប្រដារជាង និងសំលៀកបំពាក់ពិសេសដែលលោកអ្នកត្រូវការជាផ្នែកមួយនៃសកម្មភាពកម្មវិធី Welfare to Work របស់លោកអ្នក ។

បើលោកអ្នកត្រូវការការឱ្យនិវាទលើបញ្ហាផ្ទាល់ខ្លួន ដើម្បីជួយលោកអ្នកចូលរួមជាមួយកម្មវិធី Welfare to Work ហើយកិច្ចជួយផ្នែកនេះមាននៅក្នុងសហគមន៍របស់លោកអ្នក យើងនឹងណែនាំលោកអ្នកឱ្យទៅកន្លែងទាំងនោះដែលអាចជួយចំពោះលោកអ្នកបាន ។ [*Counties may insert the names of the specific entities that they will refer participants to for counseling or delete this bullet if counseling services are not available*.]

**សំគាល់** : បើសិនជាកម្មវិធី Welfare to Work បង់ថ្លៃថែរក្សាក្មេង ថ្លៃយានដឹកនាំ ឬការចំណាយលើការងារឬការហ្វឹកហ្វឺនដែលមានចំនួនច្រើនជាងលោកអ្នកត្រូវការដើម្បីចូលរួម លោកអ្នកនឹងត្រូវសងកម្មវិធី Welfare to Work វិញ ។ ប៉ុន្តែលោកអ្នកនឹងមិនបាច់បង់សងកម្មវិធី Welfare to Work វិញទេ នៅពេលដែលលោកអ្នកនៅក្នុងកម្មវិធី Welfare to Work បើសិនជាការបង់សងនេះនឹងនាំឱ្យលោកអ្នកមិនអាចចូលរួមបាន ។

## កិច្ចជួយផ្គត់ផ្គង់បន្ទាប់ពីពេលដែលលោកអ្នកទទួលការងារធ្វើ

យើងនឹងផ្តល់កិច្ចជួយផ្នែកចាត់ការលើសំណុំរឿង និងផ្នែកជួយផ្គត់ផ្គង់សំរាប់ពេល១២ខែ បន្ទាប់ពីពេលដែលលោកអ្នកបានចាប់ផ្តើមការងារ ។ យើងនឹងបង់ឱ្យតែបើសិនជាលោកអ្នកត្រូវការកិច្ចជួយនេះដើម្បីរក្សាការងាររបស់លោកអ្នក និងលោកអ្នកមិនអាចទទួលប្រាក់បង់សំរាប់កិច្ចជួយពីកន្លែងដទៃទៀត ។ [*Insert this language if your county elects to provide for job retention services in your county plan as specified in Welfare and Institutions Code, Section 11323.2.*]

## កម្មវិធីផ្តល់ជំនួយដទៃទៀត (ALTERNATIVE PAYMENT PROGRAM)

នៅពេលដែលស្ថានភាពរបស់លោកអ្នកមានសភាពមិនប្រែប្រួល ឬលោកអ្នកឈប់ទទួលជំនួយ យើងនឹងបញ្ជូនប្រាក់បង់សំរាប់កិច្ចថែរក្សាក្មេងរបស់លោកអ្នកទៅកម្មវិធីផ្តល់ជំនួយដទៃទៀតនៅក្នុងតំបន់របស់លោកអ្នក ។ លោកអ្នកនឹងមិនបាច់ផ្លាស់ប្តូរអ្នកផ្តល់កិច្ចថែរក្សាក្មេងរបស់លោកអ្នកទេ នៅពេលដែលលោកអ្នកទៅធ្វើការ ឬក្នុងដំណើរការឈប់ទទួលជំនួយ ។ បើសិនជាលោកអ្នកនៅតែត្រូវការជំនួយសំរាប់បង់ថ្លៃថែរក្សាកូនរបស់លោកអ្នក បន្ទាប់ពីលោកបានឈប់ទទួលជំនួយចំនួនពីរឆ្នាំ លោកអ្នកប្រហែលជាអាចមានសិទ្ធិទទួលជំនួយអាស្រ័យទៅលើចំនួននៃប្រាក់ចំណូលរបស់លោកអ្នក ដើម្បីបន្តទទួលជំនួយពីកម្មវិធីផ្តល់ជំនួយដទៃទៀត ។

យើងឬក៏កម្មវិធីផ្តល់ជំនួយដទៃទៀតនឹងបង់ប្រាក់ទៅឱ្យអ្នកផ្តល់កិច្ចថែរក្សាក្មេងដោយផ្ទាល់ ។

សូមជួបជាមួយអ្នកកាន់សំណុំរឿងនៃកម្មវិធី Welfare to Work របស់លោកអ្នក សំរាប់ពត៌មានបន្ថែមអំពីការឱ្យបង់ប្រាក់សំរាប់កិច្ចថែរក្សាក្មេងរបស់លោកអ្នក ។

## គ្រោងការនៃកម្មវិធី (Welfare to Work) របស់លោកអ្នក

គ្រោងការនៃកម្មវិធី Welfare to Work របស់លោកអ្នកគឺមានសារៈសំខាន់ ។ គ្រោងការនេះជំរាបលោកអ្នក អំពីរបៀបដែលលោកអ្នកហើយនិងយើងនឹងធ្វើការជាមួយគ្នា ដែលលោកអ្នកអាចប្រកួតប្រជែងនិងស្វែងរកការងារ ។ គ្រោងការនឹងធ្វើឱ្យប្រាកដថា លោកអ្នកទទួលកិច្ចជួយនិងការហ្វឹកហ្វឺនដែលបានយល់ព្រមផ្តល់ឱ្យ ឱ្យតែលោកអ្នកចូលរួមជាមួយកម្មវិធី Welfare to Work និងទទួលប្រាក់ជំនួយ ។ គ្រោងការរបស់លោកអ្នកជំរាបលោកអ្នកថាអ្វីខ្លះដែលលោកអ្នកត្រូវធ្វើ ហើយនិងអ្វីខ្លះដែលយើងត្រូវធ្វើដើម្បីធ្វើឱ្យកម្មវិធី Welfare to Work ជួយចំពោះលោកអ្នក ។

អ្នកកាន់សំណុំរឿងនៃកម្មវិធី Welfare to Work នឹងជួយលោកអ្នកពិនិត្យសាឡើងវិញលើផ្នែកនីមួយៗនៃកម្មវិធី Welfare to Work របស់លោកអ្នកដែលមានដូចតទៅនេះ :

1. **គ្រោងការនៃកម្មវិធី Welfare to Work - សិទ្ធិនិងការទទួលខុសត្រូវ** ជំរាបលោកអ្នកអំពីកម្មវិធី Welfare to Work ការទទួលខុសត្រូវរបស់យើង ហើយនិងសិទ្ធិ និងការទទួលខុសត្រូវរបស់លោកអ្នកជាអ្នកចូលរួម ។ ការព្រមព្រៀងនេះត្រូវយកមកអនុវត្តឱ្យតែលោកអ្នកនៅក្នុងកម្មវិធី Welfare to Work ។

2. កូនសៀវភៅ [*insert the county's title for the Welfare to Work Handbook*] ។

3. **គ្រោងការនៃកម្មវិធី Welfare to Work - ការចាត់ឱ្យចូលរួមជាមួយសកម្មភាព** មានជំរាបលោកអ្នកឱ្យដឹងអំពីសកម្មភាពនៃកម្មវិធី Welfare to Work ដែលលោកអ្នកកំពុងតែចូលរួមជាមួយ ។ លោកអ្នកនឹងចុះហត្ថលេខាជាមួយបេសកកម្មឱ្យចូលរួមជាមួយសកម្មភាពថ្មីមួយ សំរាប់ពេលនីមួយៗដែលលោកអ្នកចាប់ផ្តើមសកម្មភាព Welfare to Work ថ្មីមួយ ។

សូមអានផ្នែកនៃគ្រោងការនៃកម្មវិធី Welfare to Work របស់លោកអ្នក ដោយគិតបញ្ចូលទាំងកូនសៀវភៅ [*insert the county's title for the Welfare to Work Handbook*] នេះ ដោយប្រុងប្រយ័ត្ន ។ បើសិនជាលោកអ្នកមានសំណួរអ្វីមួយ សូមកុំភ្លេចសាកសួរ អ្នកកាន់ សំណុំរឿងនៃកម្មវិធី Welfare to Work របស់លោកអ្នក ។ ទាំងលោកអ្នកហើយនិងអ្នកកាន់សំណុំរឿងនៃកម្មវិធី Welfare to Work របស់លោកអ្នក នឹងចុះហត្ថលេខានៅលើបេសកកម្មនីមួយៗ ។

លោកអ្នកត្រូវតែបន្តចូលរួមជាមួយកម្មវិធី Welfare to Work បន្តពីសកម្មភាពមួយទៅសកម្មភាពមួយទៀត រហូតទាល់តែលោកអ្នកទទួលការងារធ្វើ និងក្លាយទៅជាអ្នកគ្រប់គ្រងខ្លួនដោយខ្លួនឯង ។

# ហេតុផលត្រឹមត្រូវសំរាប់ការមិនចូលរួម

យើងទទួលស្គាល់ថា លោកអ្នកអាចមានហេតុផលត្រឹមត្រូវមួយសំរាប់ការមិនចុះហត្ថលេខានៅលើគ្រោងការនៃកម្មវិធី Welfare to Work របស់លោកអ្នក សំរាប់ការមិនរួមចំណែកក្នុងផ្នែកណាមួយនៃសកម្មភាពរបស់កម្មវិធី Welfare to Work ដែលលោកអ្នកបានយល់ព្រមនៅក្នុងបេសកកម្មនៃសកម្មភាពរបស់លោកអ្នក សំរាប់ការមិនព្រមទទួលការងារដែលផ្តល់ឱ្យ ឬក៏ការងារដែលណែនាំឱ្យទៅរកសំរាប់ការលះបង់ការងារ ឬការបន្ថយប្រាក់រកបានរបស់លោកអ្នក ។ ហេតុផលខ្លះនៃហេតុផលទាំងនេះគឺបានជាប់ទាក់ទងដោយផ្ទាល់ទៅ នឹងលោកអ្នក និងខ្លះទៀតបានជាប់ទាក់ទងទៅនឹងបេសកកម្ម ។

### ហេតុផលដែលជាប់ទាក់ទងទៅនឹងលោកអ្នក :

- លោកអ្នកត្រូវការយានដឹកនាំ ឬប្រាក់បង់សំរាប់ការចំណាយទាក់ទងទៅនឹងការងារ ឬការហ្វឹកហ្វឺនដើម្បីចូលរួម ហើយកិច្ចជួយនេះមិនបានផ្តល់ឱ្យ ។

- លោកអ្នកគឺជាជនរងគ្រោះនៃអំពើឃោឃៅនៅក្នុងផ្ទះសម្បែង ហើយការចូលរួមអាចនាំឱ្យផ្តល់ទុក្ខទោសទៅដល់លោកអ្នក ហើយនិងគ្រួសាររបស់លោកអ្នក ។

- កិច្ចថែរក្សាក្មេងដែលមានច្បាប់អនុញ្ញាតឬត្រូវបានលើកលែង គឺមិនអាចចាត់ទុកជាហេតុផលសមរម្យនៅក្នុងកំឡុងពេលហ្វឹកហ្វឺនការងារ ឬ ពេលធ្វើដំណើររបស់លោកអ្នក សំរាប់ :

  - ក្មេងដែលមានអាយុ១០ឆ្នាំ ឬតិចជាង ឬ

  - ក្មេងដែលនៅក្នុងកិច្ចថែរក្សាកូនចិញ្ចឹម ឬជាក្មេងដែលទទួលជំនួយប្រាក់ជំនួយពីសហពន្ធសំរាប់មនុស្សចាស់៦៥ឆ្នាំឡើង ខ្វាក់ ឬពិការ (Supplemental Security Income ឬ SSI) ប៉ុន្តែជាអ្នកដែលមិនបានបញ្ចូលនៅក្នុងក្រុមគ្រួសារទទួលជំនួយ ។

[*Insert any additional reasons that the county wants to include.*]

### ហេតុផលដែលទាក់ទងទៅនឹងបេសកកម្មនៃសកម្មភាព ឬការងារ :

- ការប្រកែប្រកាន់នៅកន្លែងការងារ ឬហ្វឹកហ្វឺន ពីព្រោះតែអាយុ ភេទ សាសន៍ ពណ៌សម្បុរ សាសនា ជាតិឬជាតិកំណើត ពិការរូបរាងកាយឬសតិអារម្មណ៍ ការទាក់ទងផ្នែកនយោបាយ ឬស្ថានភាពរៀបការឬមិនទាន់រៀបការ ។

- ការធ្វើដំណើរទៅធ្វើការឬហ្វឹកហ្វឺនពីទីលំនៅរបស់លោកអ្នកមានរយៈពេលច្រើនជាងពីរម៉ោង ធ្វើដំណើរទៅមកតាមរថយន្តតូច រថយន្តដឹកនាំអ្នកដំណើរ ឬយានដឹកនាំដទៃទៀត ឬក៏ការទៅមកមានចម្ងាយច្រើនជាង២ម៉ៃល៍ (miles) បើលោកអ្នកត្រូវដើរពីព្រោះតែមិនមានយានដឹកនាំដទៃទៀត ។ ចំនួនកំណត់ធ្វើដំណើរ និងចំងាយផ្លូវជាម៉ៃល៍មិនគិតបញ្ចូលពេលដឹកនាំ ឬចំងាយផ្លូវដឹកនាំសមាជិកក្នុងគ្រួសារ ទៅនឹងមកពីសាលារៀន ឬទៅនិងមកពីកន្លែងអ្នកផ្តល់កិច្ចថែរក្សាក្មេងឡើយ ។ **សំគាល់** : បើសិនជាលោកមិនទទួលការងារធ្វើ ឬចូលរួមនៅក្នុងសកម្មភាពដែលបានចាត់ឱ្យចូលរួម ពីព្រោះតែមូលហេតុនេះ លោកអ្នកនឹងត្រូវតែចូលរួមនៅក្នុងការធ្វើកិច្ចការនៅក្នុងសហគមន៍ ។

- ការងារនោះបានតម្រូវឱ្យមានចំនួនម៉ោងធ្វើការក្នុងមួយថ្ងៃ ឬក្នុងមួយសប្តាហ៍ច្រើនជាងធម្មតា ឬទម្លាប់ ។

- ស្ថានភាពនៅកន្លែងធ្វើការ ឬហ្វឹកហ្វឺនបំពានទៅលើខ្នាតសុខភាព និងសន្តិសុខ ឬដែលអាចបណ្តាលឱ្យលោកអ្នកមានរបួសយ៉ាងធ្ងន់ធ្ងរ ឬស្លាប់ ។

- សកម្មភាពនៃការងារ ឬការហ្វឹកហ្វឺនមិនបានផ្តល់ការធានារ៉ាប់រងអ្នកធ្វើការពេលមានគ្រោះថ្នាក់ (Worker's Compensation Insurance) ។

- ព្រមទទួលការងារ ឬសកម្មភាពនៃការងារមួយអាចនឹងបណ្តាលឱ្យអាក់ខាន ឬរាំងស្ទះជាមួយការសិក្សាអប់រំដែលទទួលការយល់ព្រម ឬបេសកកម្មហ្វឹកហ្វឺន លើកលែងតែនេះគឺជាការងារឱ្យមានការពិសោធន៍ ឬកិច្ចការធ្វើក្នុងសហគមន៍ ។

- ព្រមទទួលការងារ ឬសកម្មភាពនៃការងារមួយអាចបណ្តាលឱ្យលោកអ្នកបំពានទៅលើលក្ខខ័ណ្ឌនៃភាពជាសមាជិកក្នុងសហជីពរបស់លោកអ្នក ។

[*Insert any additional reasons that the county wants to include.*]

## អ្វីនឹងកើតមានឡើង បើសិនជាលោកអ្នកមិនចូលរួម

ដូចដែលលោកអ្នកបានដឹងមកហើយថា ការចូលរួមជាមួយកម្មវិធី Welfare to Work គឺជាការចាំបាច់សំរាប់អ្នកសុំនិងអ្នកទទួលជំនួយ CalWORKs គ្រប់រូបដែលមានរូបកាយអាចធ្វើការបាន ។ ការលើកលែងគឺត្រូវបានចុះនៅក្នុងផ្នែកដែលមានចំណងជើង "អ្នកណាដែលមិន បាច់ចូលរួម" ។

ដោយហេតុផលណាមួយ បើសិនជាលោកអ្នកមិនបានធ្វើតាមការតម្រូវរបស់កម្មវិធី Welfare to Work វិធានការជាបន្តបន្ទាប់នឹងត្រូវបានយកមកអនុវត្ត :

**ការកំណត់លើហេតុផល** – បើលោកអ្នកមិនធ្វើតាមការតម្រូវនៃកម្មវិធី Welfare to Work លោកអ្នកមានសិទ្ធិពន្យល់ថាមកពីហេតុអ្វី ។ ខណ្ឌនឹងសំរេចថាតើមូលហេតុនេះត្រឹមត្រូវឬទេ ។ (សូមមើលផ្នែកដែលមានចំណងជើង "ហេតុផលសមរម្យសំរាប់ការមិនចូលរួម ។)

បើលោកអ្នកមានហេតុផលត្រឹមត្រូវសំរាប់ការមិនចូលរួមទៅតាមការតម្រូវរបស់ Welfare to Work អ្នកកាន់សំណុំរឿងនៃកម្មវិធី Welfare to Work របស់លោកអ្នកនឹងព្យាយាមជួយលោកអ្នក ដើម្បីឱ្យលោកអ្នកអាចអនុវត្តតាមការតម្រូវរបស់កម្មវិធី Welfare to Work ។ បើគេមិនអាចធ្វើការផ្លាស់ប្តូរដើម្បីឱ្យលោកអ្នកអាចធ្វើតាមការតម្រូវនៃកម្មវិធី Welfare to Work បានទេ លោកអ្នកនឹងមិនបានតម្រូវឱ្យចូលរួមជាមួយកម្មវិធី Welfare to Work ឡើយ ។

**ការអនុវត្តតាម** – បើលោកអ្នកមិនធ្វើតាមការតម្រូវនៃកម្មវិធី Welfare to Work យើងនឹងផ្ញើសេចក្តីប្រកាសមួយទៅជូនលោកអ្នក ។ លោកអ្នកនឹងមានពេល២០ថ្ងៃនៃប្រក្រតិទិនបន្ទាប់ពីកាលបរិច្ឆេទនៃសេចក្តីប្រកាស ដើម្បីជួបជាមួយឬទូរស័ព្ទទៅអ្នកកាន់សំណុំរឿងនៃកម្មវិធី Welfare to Work របស់លោកអ្នក ដើម្បីផ្តល់នូវមូលហេតុត្រឹមត្រូវមួយសំរាប់ការមិនធ្វើតាមអ្វីដែលលោកអ្នកបានតម្រូវឱ្យធ្វើ ឬយល់ព្រមចុះហត្ថលេខាលើគ្រោងការអនុវត្តតាមអ្វីដែលលោកអ្នកត្រូវបានតម្រូវឱ្យធ្វើ បើសិនជាលោកអ្នកមិនមានមូលហេតុសមរម្យមួយទេនោះ ។ បើសិនជាលោកអ្នកអនុវត្តតាមការតម្រូវនៃគ្រោងការ ទោសបញ្ញត្តិនឹងមិនបានអនុវត្តទៅលើលោកអ្នកឡើយ ។

**ការធ្វើទណ្ឌកម្មខាងប្រាក់កាស** – បើសិនលោកអ្នកគឺជាអ្នកចូលរួមជាចាំបាច់(សូមមើលចំណងជើងផ្នែក "អ្នកណាដែលត្រូវតែចូលរួម") ប្រាក់ជំនួយរបស់គ្រួសារលោកអ្នកនឹងត្រូវបានបន្ថយ បើលោកអ្នកមិនបានឬបដិសេធក្នុងការធ្វើតាមការតម្រូវរបស់កម្មវិធី Welfare to Work ដោយមិនមានហេតុផលត្រឹមត្រូវ ហើយមិនដោះស្រាយបញ្ហាដោយការចុះហត្ថលេខា និងបំពេញលើគ្រោងការអនុវត្តតាម ។

ប្រាក់ជំនួយនៃគ្រួសាររបស់លោកអ្នកនឹងត្រូវបានបន្ថយ បើសិនជាអ្នកណាម្នាក់ដែលត្រូវចូលរួមមិនអនុវត្តតាមការតម្រូវនៃកម្មវិធី Welfare to Work ។ ការធ្វើទណ្ឌកម្មផ្នែកប្រាក់កាសនេះនឹងកើតមានឡើង នៅពេលណាតែអ្នកណាម្នាក់ដែលមិនមានហេតុផលត្រឹម ត្រូវ ឬគេមិនបានចុះហត្ថលេខា ឬបំពេញគ្រោងការអនុវត្តតាម ។ អ្នកទទួលទណ្ឌកម្មផ្នែកប្រាក់កាសនឹងមិនបានទទួលប្រាក់ជំនួយសំរាប់ពេលមួយរយៈ ។

បើសិនជាក្រុមគ្រួសារលោកអ្នកគឺជាគ្រួសារដែលមានទាំងឪពុកនិងម្តាយ ហើយទទួលប្រាក់ជំនួយ ដោយសារតែការមិនមានការងារធ្វើ គឺមានច្បាប់ពិសេសសំរាប់ការធ្វើទណ្ឌកម្មផ្នែកប្រាក់កាស ។ បើសិនជាឪពុកឬម្តាយដែលត្រូវចូលរួមជាមួយ Welfare to Work បណ្តាលឱ្យមានទណ្ឌកម្មផ្នែកប្រាក់កាស ទាំងឪពុកនិងម្តាយទាំងពីរនាក់នឹងបាត់បង់ប្រាក់ជំនួយរបស់គេ ។ ក៏ប៉ុន្តែឪពុកឬម្តាយដែលមិនបានបណ្តាលឱ្យមានទណ្ឌកម្មផ្នែកប្រាក់កាសអាចនៅបន្តទទួលប្រាក់ជំនួយរបស់គាត់ បើសិនជាគាត់ចូលរួមជាមួយកម្មវិធី Welfare to Work ឬត្រូវបានគេលើកលែង ឬមានហេតុផលត្រឹមត្រូវសំរាប់ការមិនចូលរួម ។

នៅពេលដំបូងដែលលោកអ្នកត្រូវបានទទួលទណ្ឌកម្ម ជំនួយនៃគ្រួសាររបស់លោកអ្នកនឹងត្រូវបានបន្ថយរហូតទាល់តែលោកអ្នកបានធ្វើតាមអ្វីដែលកម្មវិធី Welfare to Work បានតម្រូវ និងដាក់ពាក្យសុំប្រាក់ជំនួយឡើងវិញ ។ នៅលើកទី២ ប្រាក់ជំនួយនៃគ្រួសាររបស់លោកអ្នកនឹងត្រូវបានបន្ថយយ៉ាងតិចណាស់ចំនួន៣ខែ ។ បន្ទាប់ពីពេល៣ខែ ទណ្ឌកម្មនេះនឹងបញ្ឈប់ បើសិន ជាលោកអ្នកដាក់ពាក្យសុំប្រាក់ជំនួយឡើងវិញ និងធ្វើតាមអ្វីដែលកម្មវិធី Welfare to Work បានតម្រូវ ។ នៅលើកទី៣ ឬលើសពីនេះ ប្រាក់ជំនួយគ្រួសាររបស់លោកអ្នកនឹងត្រូវបានបន្ថយសំរាប់ពេលយ៉ាងតិចណាស់៦ខែ ។ ក្រោយពេល៦ខែ ទណ្ឌកម្មនេះនឹងបានបញ្ឈប់ បើសិនជាលោកអ្នកដាក់ពាក្យសុំប្រាក់ជំនួយឡើងវិញ និងធ្វើតាមការតម្រូវនៃកម្មវិធី Welfare to Work ។

**ទោសបញ្ញត្តិចំពោះអ្នកស្ម័គ្រចិត្ត** – អ្នកណាម្នាក់ដែលត្រូវបានលើកលែងពីការចូលរួមជាមួយកម្មវិធី Welfare to Work (សូមអានចំណងជើងនៃផ្នែក"អ្នកណាដែលមិនបាច់ចូលរួម") អាចជ្រើសរើសស្ម័គ្រចិត្តចូលរួមជាមួយកម្មវិធី Welfare to Work ។ បើសិនជាលោកអ្នកស្ម័គ្រចិត្តចូលរួមជាមួយកម្មវិធី Welfare to Work ប៉ុន្តែមិនធ្វើតាមការតម្រូវដោយពុំមានហេតុផលត្រឹមត្រូវ លោកអ្នកនឹងមិនបានអនុញ្ញាតឱ្យចូលរួមជាមួយកម្មវិធី Welfare to Work សំរាប់ពេលមួយរយៈ ។

សូមទាក់ទងទៅអ្នកកាន់សំណុំរឿងនៃកម្មវិធី Welfare to Work របស់លោកអ្នក បើសិនជាលោកអ្នកមានសំណួរអ្វីមួយទាក់ទងទៅនឹងការតម្រូវទាំងនេះ ។

# ការទៅសាលារៀននៃកូនរបស់លោកអ្នក

បើសិនជាកូនរបស់លោកអ្នកត្រូវតែទៅសាលារៀន និងដែលយើងសំរេចថា ក្មេងនោះមិនបានទៅរៀនជាទៀងទាត់ (លើកលែងតែក្មេងមានសិទ្ធិចូលរួមជាមួយកម្មវិធី Cal-Learn) [*San Diego and Merced counties also should include children participating in school attendance projects.*] ប្រាក់ជំនួយនៃគ្រួសាររបស់លោកអ្នកក៏នឹងបន្ថយផងដែរ ។ លោកអ្នកត្រូវតែបង្ហាញភស្តុតាងថា កូនរបស់លោកអ្នកទៅសាលារៀនយ៉ាងទៀងទាត់ បើសិនជាយើងសួររក ។

# អ្វីដែលលោកអ្នកអាចធ្វើ បើសិនជាលោកអ្នកមិនយល់ស្រប

មានសកម្មភាពបីយ៉ាងដែលលោកអ្នកអាចយកមកប្រើ បើសិនជាលោកអ្នកមិនយល់ស្របជាមួយនឹងសេចក្តីសំរេចរបស់យើង ។

1. **សេចក្តីបំភ្លឺពីរដ្ឋ** – បើសិនជាលោកអ្នកមិនយល់ស្របជាមួយនឹងសេចក្តីសំរេចរបស់ខណ្ឌទាក់ទងទៅនឹងទោសបញ្ញត្តិនៃកម្មវិធី Welfare to Work (សូមអានចំណងជើងនៃផ្នែក"ហេតុផលសមរម្យសំរាប់ការមិនចូលរួម") ស្ថានភាព(ការចូលរួម)របស់លោកអ្នកនៅក្នុងកម្មវិធី Welfare to Work សកម្មភាពនៃកម្មវិធី Welfare to Work របស់លោកអ្នក ឬកិច្ចជួយផ្គត់ផ្គង់នៃកម្មវិធី Welfare to Work របស់លោកអ្នក លោកអ្នកអាចស្នើសុំសេចក្តីបំភ្លឺពីរដ្ឋ ។ សំរាប់ការធ្វើទណ្ឌកម្មផ្នែកប្រាក់កាសនៃកម្មវិធី Welfare to Work លោកអ្នកអាចប្រើដំណើរការដូចគ្នាទៅនឹងដំណើរការដែលលោកអ្នកមិនយល់ស្របជាមួយនឹងសកម្មភាពណាដែលខណ្ឌបានអនុវត្តទៅលើប្រាក់ជំនួយរបស់លោកអ្នក ។ អ្នកកាន់សំណុំរឿងនៃកម្មវិធី Welfare to Work របស់លោកអ្នកនឹងជួយលោកអ្នកបំពេញសេចក្តីបំភ្លឺពីរដ្ឋ បើសិនជាលោកអ្នកចង់បាន ។ លោកអ្នកអាចស្នើសុំសេចក្តីបំភ្លឺជាថ្មីមួយទៀត បន្ទាប់ពីមានសេចក្តីសំរេចលើសេចក្តីបំភ្លឺពីរដ្ឋរួចមក ។

   - បើលោកអ្នកដាក់ពាក្យតវ៉ាសុំសេចក្តីបំភ្លឺពីរដ្ឋមួយ នៅមុនពេលទោសបញ្ញត្តិបានចាប់ផ្តើម ទោសបញ្ញត្តិនឹងមិនបានយកមកអនុវត្តទេ នៅក្នុងពេលកំពុងធ្វើការសំរេចលើសេចក្តីបំភ្លឺ ។

   - បើសិនជាលោកអ្នកដាក់ពាក្យសុំសេចក្តីបំភ្លឺពីរដ្ឋសំរាប់សកម្មភាពដទៃទៀតរបស់ខណ្ឌ ច្បាប់ផ្សេងទៀតនឹងយកមកអនុវត្ត ។ សំណៅស្តីអំពីសិទ្ធិរបស់លោកអ្នកក្នុងការស្នើសុំសេចក្តីបំភ្លឺទាក់ទងទៅនឹងកម្មវិធី Welfare to Work មានពន្យល់អំពីច្បាប់ទាំងនេះ ។ លោកអ្នក អាចស្នើសុំសេចក្តីចម្លងនៃសំណៅនេះបានគ្រប់ពេល ។

2. **ការប្រមាណប៉ាន់ដោយអ្នកមិនទាក់ទងផ្សេងទៀត** – បើសិនជាលោកអ្នកមិនយល់ស្របជាមួយនឹងលទ្ធផលនៃការប្រមាណប៉ាន់ ឬ គ្រោងការកម្មវិធី Welfare to Work របស់លោកអ្នក មនុស្សម្នាក់ដែលមិនមែនជាអ្នកតំណាងនៃខណ្ឌនឹងពិនិត្យលើការប្រមាណប៉ាន់របស់លោកអ្នកសាឡើងវិញ ហើយនឹងធ្វើការប្រមាណប៉ាន់មួយទៀត បើសិនជាការចាំបាច់ ។ លទ្ធផលនៃការប្រមាណប៉ាន់ដោយមិនពឹងផ្អែកនេះ នឹងយកមកប្រើដើម្បីរៀបចំគ្រោងការកម្មវិធី Welfare to Work របស់លោកអ្នក ។

   - បើសិនជាលោកអ្នកបានធ្វើការប្រមាណប៉ាន់ដោយអ្នកមិនទាក់ទងផ្សេងទៀត ទោសបញ្ញត្តិនឹងមិនបានអនុវត្តទៅលើលោកអ្នកទេ នៅក្នុងគ្រាដែលលោកអ្នករង់ចាំលទ្ធផលនៃការពិនិត្យសាឡើងវិញ ។

3. **សាទុក្ខជាផ្លូវការដែលបង្កើតឡើងដោយក្រុមប្រឹក្សាអ្នកត្រួតត្រានៃខណ្ឌ** – នេះគឺជាដំណើរការដែលបានបង្កើតឡើងដោយក្រុមប្រឹក្សាអ្នកត្រួតត្រានៃ [*insert the name of the county*] ។ អ្នកកាន់សំណុំរឿងនៃកម្មវិធី Welfare to Work របស់លោកអ្នកនឹងជំរាបអំពីរបៀប ដំណើរការនៃសាទុក្ខនេះដែលនឹងប្រព្រឹត្តទៅរបៀបណា ។

   - បើសិនជាលោកអ្នកប្រើដំណើរការសាទុក្ខជាផ្លូវការ លោកអ្នកត្រូវតែបន្តធ្វើតាមការតម្រូវនានានៃកម្មវិធី Welfare to Work ។ បើសិនជាលោកអ្នកធ្វើតាម ទោសបញ្ញត្តិនឹងមិនបានយកមកអនុវត្តទេ នៅក្នុងពេលដែលគេកំពុងធ្វើការសំរេចលើពាក្យបណ្តឹង ។